01206342



ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 02 / 2016
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចស្តីអំពីសវនាការអសាធារណៈសម្រាប់សាក្សី 2-TCW-894 និង 2-TCW-938

1. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សាក្សី 2-TCW-894 និង 2-TCW-938 ដែលពួកគាត់ទាំងពីរនាក់ត្រូវបានស្តាប់ចម្លើយនៅក្នុងបរិបទនៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នោះ នឹងផ្តល់សក្ខីកម្មនៅក្នុងសវនាការអសាធារណៈស្របតាមអនុស្សរណៈ E319/35 របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦)។ ភាគីទទួលបានការជូនដំណឹងថា សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះនឹងចេញនៅពេលក្រោយក្នុងពេលសមស្រប។ បន្ទាប់មកទៀត អង្គជំនុំជម្រះទទួលបានអនុស្សរណៈសម្ងាត់មួយពី ស.ច.ស.អ ដែលបញ្ជាក់អំពីការរក្សាជំហរពីមុនរបស់គាត់ស្តីអំពីលក្ខខណ្ឌដែលត្រូវអនុវត្តសម្រាប់សួរដេញដោលសាក្សី ដូចដែលបានកំណត់នៅក្នុងឯកសារ E319/35 (E319/35/4)។ បន្ទាប់ពីមានសំណើជាច្រើនដងពីសហព្រះរាជ-

អាជ្ញាអន្តរជាតិសុំឱ្យធ្វើសវនាការពិភាក្សាអំពីបញ្ហានេះ (រួមមានឯកសារ E384) អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់ពីភាគីទាំងអស់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦។ នៅក្នុងថ្ងៃដដែលនោះដែរ អង្គជំនុំ-ជម្រះបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់មួយ ដោយតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការបន្តដំណើរការសវនាការអសាធារណៈសម្រាប់សាក្សីទាំងពីរនាក់នេះ (ប្រតិចារឹកសវនាការថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ៦-៧ (សាធារណៈ))។ ខាងក្រោមនេះគឺជាសំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ។

2. អង្គជំនុំជម្រះរំលឹកថា នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នៅក្នុងអនុស្សរណៈមួយស្តីអំពីការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២ (ឯកសារ E319/35) ស.ច.ស.អ បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា បន្ទាប់ពីការពិនិត្យលើភ័ស្តុតាងដែលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូនរួចមក គាត់នឹងស្នើសុំឱ្យប្រើប្រាស់សវនាការអសាធារណៈ និង វិធានការផ្សេងៗទៀតដែលចាំបាច់ក្រៅពីការប្រើប្រាស់រហស្សនាម សម្រាប់សាក្សីមួយចំនួនតូចដែល "សំខាន់ផ្ទាល់នៅក្នុងកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៣ ឬ ០០៤" "ដើម្បីធានាសុចរិតភាពនៃភ័ស្តុតាង" (ឯកសារ E319/35 កថាខណ្ឌ ៣.គ)។ សាក្សីទាំងនេះត្រូវបានហៅថាជា "សាក្សីប្រភេទ គ"។ អនុស្សរណៈ E319/35 មិនកំណត់ត្រឹមភ័ស្តុតាងដែលអនុញ្ញាតឱ្យមានការដាក់បង្ហាញដោយលោកចៅក្រម Bohlander នោះឡើយ ប៉ុន្តែជាទូទៅពាក់ព័ន្ធទៅនឹងភ័ស្តុតាងទាំងអស់ដែលត្រូវបានដាក់បង្ហាញពីក្នុងសំណុំរឿង ០០៣ និង ០០៤។

3. នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានទទួលព័ត៌មានថា ស.ច.ស.អ បានបញ្ជាក់ថាសាក្សី 2-TCW-938 និង 2-TCW-894 គឺជាសាក្សីប្រភេទ គ។ ដូចដែលបានកំណត់នៅក្នុងឯកសារ E319/35 កថាខណ្ឌ ៣.គ លក្ខខណ្ឌនៃការប្រើប្រាស់សម្រាប់សាក្សីប្រភេទ គ នេះគឺ ៖ ការប្រើប្រាស់រហស្សនាម និង ការផ្តល់សក្ខីកម្មនៅក្នុងសវនាការអសាធារណៈ។

4. អង្គជំនុំជម្រះរំលឹកថា អនុលោមតាមមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធាន ៧៩(៦) នៃវិធានផ្ទៃក្នុង សវនាការត្រូវតែធ្វើឡើងជាសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានទទួលស្គាល់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង អនុលោមតាមច្បាប់អន្តរជាតិ សិទ្ធិទទួលបានសវនាការជាសាធារណៈមិនមានលក្ខណៈដាច់ខាតនោះឡើយ។ នៅក្នុងកាលៈទេសៈពិសេសដែលផល-ប្រយោជន៍យុត្តិធម៌តម្រូវ តុលាការអាចសម្រេចអនុវត្តកិច្ចដំណើរការនីតិវិធីជាអសាធារណៈ (មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR) ដែលកម្ពុជាជារដ្ឋភាគី ចែងថា

សាធារណជនអាចមិនឱ្យចូលរួមទាំងស្រុង ឬ ផ្នែកមួយនៃសវនាការ "ក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការក្នុងស្ថានភាពពិសេសដែលការធ្វើសវនាការជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌")។ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អង្គជំនុំជម្រះអាចធ្វើការជំនុំជម្រះជាសម្ងាត់ ដោយមានមូលហេតុត្រឹមត្រូវ អនុលោមតាមនីតិវិធីជាធរមាន ប្រសិនបើការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។ អនុលោមតាមវិធាន ៧៩(៦)(ខ) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចបង្គាប់ថា សវនាការត្រូវធ្វើជាសម្ងាត់នៅពេលដែលក្នុងចំណោមមូលហេតុផ្សេងទៀត សវនាការជាសាធារណៈអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ។

5. អង្គជំនុំជម្រះយល់ឃើញថា ការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការអាចជា "មូលហេតុត្រឹមត្រូវ" សម្រាប់កិច្ចដំណើរការនីតិវិធីជាអសាធារណៈ។ នៅក្នុងករណីនេះ ការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ អាចត្រូវបានធានាតែតាមរយៈការស្តាប់សក្ខីកម្មសាក្សី 2-TCW-938 និង 2-TCW-894 នៅក្នុងសវនាការអសាធារណៈប៉ុណ្ណោះ។ អង្គជំនុំជម្រះផ្អែកសំអាងហេតុនេះទៅលើការអះអាងរបស់ ស.ច.ស.អ ដែលថា "ការដាក់បង្ហាញភស្តុតាងរបស់ពួកគាត់នៅក្នុងសវនាការសាធារណៈនឹងប៉ះពាល់ដល់កិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ ពីព្រោះថា វាអាចធ្វើឱ្យមានគ្រោះថ្នាក់ក្នុងការស្តាប់ចម្លើយពួកគាត់នាពេលអនាគត ឬ ក៏ការស្តាប់ចម្លើយជនដែលមានតម្រុយភស្តុតាងបន្ទាប់ពីការស្តាប់ចម្លើយពួកគាត់" (ឯកសារ E319/35 កថាខណ្ឌ ៣.គ)។ នៅក្នុងដំណាក់កាលនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាការិយាល័យតែមួយគត់ដែលអាចធ្វើការវាយតម្លៃបែបនេះ នៅក្នុងពេលវេលាសមស្រប ដោយសារតែការិយាល័យនេះមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និង យល់ដឹងអំពីយុទ្ធសាស្ត្រស៊ើបអង្កេត។ អង្គជំនុំជម្រះពុំមានហេតុផលក្នុងការយល់ឃើញថា ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃត្រឹមត្រូវនោះឡើយ ដូច្នេះហើយ អង្គជំនុំជម្រះផ្អែកទៅលើការវាយតម្លៃរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិនេះ។

6. ដោយកត់សម្គាល់ឃើញនូវអត្ថិភាពនៃមូលហេតុត្រឹមត្រូវសម្រាប់កិច្ចដំណើរការនីតិវិធីក្នុងសវនាការអសាធារណៈ អង្គជំនុំជម្រះក៏រំលឹកផងដែរថា វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង តម្រូវថា កិច្ចស៊ើបសួរត្រូវស្ថិតនៅជាសម្ងាត់ និង យល់ឃើញថា ការរំលោភបំពានលើភាពសម្ងាត់នេះអាចជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដែលអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ (ឯកសារ E319/7/3)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-938 និង 2-TCW-894 គួរធ្វើឡើងនៅក្នុងសវនាការអសាធារណៈទាំងស្រុង អនុលោមតាមមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធាន ៧៩(៦)(ខ) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងការ

វាយតម្លៃគោលការណ៍ជាសារវ័ន្តដែលថា ការជំនុំជម្រះក្តីក្នុងរឿងព្រហ្មទណ្ឌគួរធ្វើឡើងនៅក្នុងសវនាការជាសាធារណៈ និង តម្រូវការក្នុងការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរនោះ ការដាក់កំហិតណាមួយទៅលើលក្ខណៈសាធារណៈនៃកិច្ចដំណើរការនីតិវិធី ត្រូវតែពាក់ព័ន្ធទៅនឹងបញ្ហាដែលចាំបាច់បំផុតដើម្បីផលប្រយោជន៍យុត្តិធម៌។ ដើម្បីធ្វើឱ្យសវនាការទាំងនេះមានលក្ខណៈសាធារណៈក្នុងកម្រិតអតិបរមានោះ អង្គជំនុំជម្រះនឹងកោសលុបប្រតិចារឹកសវនាការអសាធារណៈ ដោយពិគ្រោះយោបល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សូមមើល ឯកសារ E319/35/2 កថាខណ្ឌ ៤) ដើម្បីអាចឱ្យប្រតិចារឹកសវនាការទាំងនេះដាក់ផ្សាយជាសាធារណៈបាន។ លើសពីនេះទៀត ផ្នែកសម្ងាត់នៃប្រតិចារឹកទាំងនេះ អាចត្រូវបានចាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនៅពេលក្រោយទៀត ប្រសិនបើហេតុផលដែលផ្តល់យុត្តិកម្មចំពោះការកោសលុបប្រតិចារឹកទាំងនោះ លែងមានភាពចាំបាច់ហើយនោះ។